**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
លេខ:០១៣ /០៨ កហ អ.គ.គ

# កំណត់ហេតុ ស្តីពី កម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់លើសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល សិក្ខាសាលានៅខេត្តកំពង់ធំ និងខេត្តព្រះវិហារ

ឆ្នាំពីរពាន់ប្រាំបី ខែ មេសា ថ្ងៃទី ដប់ វេលាម៉ោងប្រាំបី នៅសាលាខេត្តកំពង់ធំ មានរៀបចំសិក្ខាសាលាមួយ ក្រោមអធិបតីភាពឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីផ្សព្វផ្សាយកម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់លើសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល។ ចូលរួមជាគណៈធិបតីក្នុងឱកាស នោះមាន ឯកឧត្តម ឈុន ឈន់ អភិបាលរងខេត្តកំពង់ធំ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ឈុន ឈន់ អភិបាលរងខេត្តកំពង់ធំ បានសម្តែងកិច្ចស្វាគមន៍ចំពោះគណៈអធិបតីគណៈប្រតិភូនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងថ្នាក់ដឹកនាំ មន្ត្រីរាជការនៅតាមមន្ទីរជំនាញផ្សេងៗ ជុំវិញខេត្តកំពង់ធំ និងខេត្តព្រះវិហារ ដែលមានវត្តមាននៅក្នុងអង្គសិក្ខាសាលា ព្រមទាំងថ្លែងអំណរគុណដល់អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងធ្វើបទបង្ហាញជូនដល់មន្ត្រីរាជការនៃអង្គភាពជំនាញផ្សេងៗរបស់ខេត្ត ឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត អំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកែទម្រង់ច្បាប់ និងតុលាការ ។ ឯកឧត្តម បានបញ្ជាក់ថា អង្គសិក្ខាសាលានាពេលព្រឹកនេះ គឺត្រូវបានរៀបចំឡើង ដើម្បីផ្សព្វផ្សាយ និងចែករំលែក បទពិសោធន៍ផ្សេងៗនៃការកែទម្រង់ច្បាប់ និងតុលាការ ជូនមន្ត្រីរាជការក្នុងខេត្តខណៈដែលរាជរដ្ឋាភិបាលកំពុង តែធ្វើដំណើរឆ្ពោះទៅមុខប្រកបដោយឆន្ទៈដ៏មោះមុត ជាមួយនឹងកម្មវិធីនយោបាយកំណែទម្រង់រដ្ឋ ដែលជា សមាសធាតុគន្លឹះនៃអភិបាលកិច្ចល្អស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៣នៃរដ្ឋសភា ។

ជាបន្ទាប់ ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើបទអន្តរាគម៍ជម្រាបជូនអង្គសិក្ខាសាលាអំពីដំណើរការនៃការកែទម្រង់ច្បាប់ និង តុលាការ និងការរៀបចំរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលបានបង្កើតឡើង នៅថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម ឌិត មន្ទី ប្រធានតុលាការកំពូលជាសហប្រធាន ។ ឯកឧត្តមបានបង្ហាញជូនអង្គប្រជុំ អំពីអង្គភាពផ្សេងៗរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលរួមមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (PCB) បង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ និងអង្គភាពគ្រប់គ្រងគម្រោង ( PMU ) បង្កើតឡើងនៅ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទី ជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ឯកឧត្តមបានលើកឡើងពីគោលដៅ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងការបង្កើតផែនការសកម្មភាពចក្ខុវិស័យទស្សនាទាន គឺចង់អោយវិស័យច្បាប់ និងតុលាការរបស់យើងមានភាពរឹងមាំ និងជាទីទុកចិត្តរបស់ប្រជាពលក្នុងការដោះស្រាយទំនាស់ផ្សេងៗ ហើយក៏ដើម្បីទ្រទ្រង់គោលការណ៍សិទ្ធិបុគ្គល ការបែងចែកអំណាចដាច់ពីគ្នា និងនីតិរដ្ឋ នៅក្នុងលិទ្ធិប្រជាធិបតេយ្យសេរី តាមរយៈការលើកស្ទួយនូវការរីកចំរើនសេដ្ឋកិច្ចនាំមុខដោយវិស័យឯកជន ។ ជាមួយគ្នានោះដែរ ឯកឧត្តមបានជម្រាបជូនអំពីការអនុម័តលើឯកសារស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានអនុម័តនូវកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥។

លោក ឡេង សុខុន ប្រធានតុលាការខេត្តកំពង់ធំ បានជម្រាបជូនអង្គប្រជុំអំពីស្ថានភាពជាក់ស្ដែងជាសង្ខេបរបស់តុលាការខេត្តកំពង់ធំ ។ លោកបានបញ្ជាក់ថា តុលាការខេត្តកំពង់ធំមានដំណើរការស្របតាមកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការរបស់រដ្ឋ បានទទួលការបណ្តុះបណ្តាលនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ តាំងពីចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីជាដើម បានធ្វើការអនុវត្តស្របតាមក្រមថ្មី ដែលត្រូវបានចូលជាធរមាន ។ លោកបានជម្រាបផងដែរថា តុលាការខេត្តកំពង់ធំបច្ចុប្បន្នមានចៅក្រម៥នាក់ ព្រះរាជអាជ្ញា២រូប និងក្រឡាបញ្ជី១នាក់ ហើយលោកបានបញ្ជាក់ថា ចៅក្រម ១នាក់ដោះស្រាយរឿងក្តីពី ៣០០ ទៅ៤០០ សំណុំរឿង ។ បញ្ហាច្បាប់ដែលត្រូវចូលជាធរមាន មានការផ្លាស់ប្តូរ រមែងជួបប្រទៈនឹងការលំបាកខ្លះៗ ប៉ុន្តែមន្ត្រីតុលាការត្រូវបានទទួលការបណ្តុះបណ្តាលជាបន្តបន្ទាប់ នៅសាលាវិជ្ជាជីវៈ តុលាការ ។

លោក អ៊ូច វ៉ាន់អេន ប្រធានតុលាការព្រះវិហារ ក៏បានធ្វើការសង្ខេបទាក់ទិនទៅនឹងស្ថានភាពកំណែទម្រង់ និងបញ្ហាប្រឈមមុខដែលទាក់ទងទៅនឹងតុលាការខេត្តព្រះវិហារដែរ ។ លោកបានមានប្រសាសន៍ថា តុលាការព្រះវិហារមានក្រឡាបញ្ជីតែបីនាក់ទេ ម្នាក់ទទួលបន្ទុកផ្នែកគណនេយ្យម្នាក់ទៀតទទួលផ្នែករដ្ឋប្បវេណី និងមួយរូបទៀតទទួលបន្ទុកផ្នែកព្រហ្មទណ្ឌ ។ លោកប្រធានតុលាការក៏បានលើកឡើងពបញ្ហាលំបាកដែលក្រឡាបញ្ជី និងចៅក្រមទទួលបន្ទុក ការងារដ៏ច្រើនលើសលុប ។ ដូច្នេះលោកបានស្នើសុំអោយ ក្រុមប្រឹក្សាជួយញ៉ាំនាំបញ្ហាទាំងនេះជម្រាបជូនទៅថ្នាក់លើផង ។ ចំពោះបញ្ហាធនធានមនុស្សតុលាការខេត្ត ព្រះវិហារ ត្រូវបានទទួលការបណ្តុះបណ្តាលដូចតុលាការកំពង់ធំផងដែរ ។

ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានស្វាគមន៍ចំពោះរបាយការណ៍អំពីស្ថានភាពជាក់ស្តែងរបស់តុលាការខេត្តទាំងពីរ នឹងបានធ្វើការសរសើរលើកទឹកចិត្ត អោយបន្តការងារកំណែទម្រង់ច្បាប់ និងតុលាការ ស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលនេះអោយបានកាន់តែខ្លាំងក្លាថែមទៀត ។ ជាបន្ទាប់ឯកឧត្តមបានធ្វើបទបង្ហាញអំពីភាពជឿនលឿននៃការអនុវត្តកម្មវិធីសកម្មភាពយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងតុលាការកម្ពុជាទៅតាមទិសដៅជាយុទ្ធសាស្រ្តទាំង៧ ។ ដោយសកម្មភាពជាអាទិភាពមានច្រើនពេក សរុបសកម្មភាពនោះទាំងអស់ ៩៧ ឯកឧត្តមបានសុំការអនុញ្ញាតិពីអង្គប្រជុំលើកយកតែចំណុចខ្លះៗ មកបង្ហាញជូនដូចខាងក្រោម៖

1- ទិសដៅជាយុទ្ធសាស្រ្តទី១ ៖ ស្តីពីការការពារសិទ្ធិសេរីភាពរបស់បុគ្គល ចំណុចសំខាន់ក្នុងទិសដៅនេះ គឺការបង្កើនការយល់ដឹងអំពីសិទ្ធិមូលដ្ឋាន និងពលរដ្ឋវិជ្ជា។ ទិសដៅជាយុទ្ធសាស្រ្តទី១ មានចំនួន ១៩ សកម្មភាព ក្នុងនោះមានសកម្មភាព រយៈពេលខ្លីចំនួន ០៥ សកម្មភាព ចំណែករយៈពេលមធ្យម មានចំនួន ០៦ សកម្មភាព និងសកម្មភាពរយៈពេលវែងមានចំនួន ០៨ សកម្មភាព ។
2- ទិសដៅជាយុទ្ធសាស្រ្តទី២ ៖ ស្តីពីធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ ឯកឧត្តមមាន ប្រសាសន៍ថា យើងបានអនុម័តច្បាប់ចំនួន ១១៨ ច្បាប់ នៅក្នុងអាណត្តិទី៣ នៃរដ្ឋសភានេះ ក្នុងនោះមានច្បាប់ជាមូលដ្ឋាន សម្រាប់តុលាការដូចជាក្រម នីតិវិធីរដ្ឋប្បវេណីក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ។
3- ទិសដៅជាយុទ្ធសាស្រ្តទី៣ស្តីពីការផ្តល់លទ្ធភាពអោយទទួលបានព័ត៌មានច្បាប់ និងតុលាការអោយ កាន់តែប្រសើរឡើង បច្ចុប្បន្ននេះយើងកំពុងតែសហការជាមួយបារាំង និង UNDP ធ្វើយ៉ាងណាអោយច្បាប់នានាបានទៅដល់ប្រជាពលរដ្ឋ ដោយមានអគ្គនាយកដ្ឋានរាជកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាអ្នកដែលកំពុងធ្វើកិច្ចការនេះយ៉ាងសកម្ម។
4- ទិសដៅជាយុទ្ធសាស្រ្តទី៤ស្តីពីការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃរឿងក្តី និងសេវាពាក់ព័ន្ធ ការងារគន្លឹះក្នុងយុទ្ធសាស្រ្តនេះ គឺការផ្តល់មេធាវីជូនជនក្រីក្រ ការបង្កើនសេវាជំនួយផ្នែកច្បាប់ និងតំណាងផ្នែកច្បាប់អោយបានដល់ប្រជាពលរដ្ឋទាំងអស់ ។

គណៈមេធាវីមាននាយកដ្ឋានមួយទទួលបន្ទុករឿងនេះ ហើយអង្គភាពគ្រប់គ្រងគម្រោងបានសហការជាមួយ EWMI (UsAid) ធ្វើការសិក្សាស្ទង់មតិ អំពីជំនួយផ្នែកច្បាប់នេះរួច ហើយដែរ ។

5- ទិសដៅជាយុទ្ធសាស្ត្រទី៥ ៖ **ពង្រឹងសេវាយុត្តិធម៌ រួមមានអំណាចតុលាការ និង សេវាអយ្យការ ៖** ការងារដែលមមាញឹកក្នុងទិសដៅនេះ គឺការរៀបចំតុលាការគំរូ ក្រោមជំនួយឧបត្ថម្ភរបស់ UsAid និង CCJAP

6- ទិសដៅជាយុទ្ធសាស្ត្រទី៦ ៖ **បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ទាក់ទងនឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ សហការជាមួយ UNDP បានសិក្សារៀបចំ និងបង្កើតមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌នៅតាមស្រុកចំនួន ០៤ នៅខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង នឹងគ្រោងបន្តទៅខេត្ត ដ៏ទៃទៀតបង្គ្រប់ចំនួន២០ ។

7- ទិសដៅជាយុទ្ធសាស្ត្រទីក៧ស្តីពីការពង្រឹងស្ថាប័នវិស័យច្បាប់ **និងតុលាការដើម្បីបំពេញអាណត្តិខ្លួនបានសម្រេច** ។ ការងារដែលមមាញឹកក្នុងទិសដៅនេះ គឺការរៀបចំសៀវភៅណែនាំសម្រាប់យើងទាំងមូល និងការបណ្តុះបណ្តាលអ្នកពាក់ព័ន្ធ ដើម្បីបង្កើនល្បឿននៃកំណែទម្រង់ ហើយនឹងការរៀបចំប្រព័ន្ធសូចនាករតាមដានការអនុវត្តកំណែទម្រង់ ។

លោក ស៊ុយ សារិទ្ធ អភិបាលរងខេត្តព្រះវិហារ បានលើកឡើងអំពីយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ក្នុងទិសដៅជាយុទ្ធសាស្ត្រទី០៦) ទាក់ទិនរឿងវិវាទដីធ្លីដោយលោកបានលើកឡើងថា រឿងនេះកើតឡើងសឹងតែទូទាំងប្រទេស ដូច្នេះតើស្ថាប័នណាមួយដែលអាចដោះស្រាយជូនប្រជាពលរដ្ឋបានច្បាស់លាស់នោះ ? ។ បញ្ហាមួយទៀត លោកបានមានប្រសាសន៍ថាមិនឃើញមាននៅក្នុងយុទ្ធសាស្ត្រទាំង០៧នេះ គឺថាតុលាការអាចដាក់ទោស ឬឃុំខ្លួននរណាម្នាក់រហូតដល់ពេលតុលាការរកឃើញថា គ្មានទោសកំហុសសូវថា តើមាននីតិវិធីណាដែលអាចដាក់ទោសចំពោះតុលាការ ដែលបានប្រព្រឹត្តខុសក្នុងរឿងនេះបាន ?

ឯកឧត្តម ស៊ុយ ម៉ុងលាង បានឆ្លើយតបថា បញ្ហាតុលាការ គឺមានតែស្ថាប័នតុលាការមួយគត់ជាអ្នកដោះស្រាយ ហើយទាក់ទិននឹងការដោះស្រាយបញ្ហាវិវាទទាំងអស់ ឯកឧត្តមប្រធានបានជម្រាបថា បច្ចុប្បន្ននេះប្រជាពលរដ្ឋខ្លះ មិនទាន់បានយល់អំពីសិទ្ធិរបស់ខ្លួនច្បាស់លាស់ទេ ដែលជាហេតុធ្វើអោយសង្គមរបស់យើងជួបបញ្ហាជាច្រើន ។ ក្នុងការដោះស្រាយបញ្ហាយុត្តិធម៌នៅថ្នាក់មូលដ្ឋាននេះ ឯកឧត្តម បានបំភ្លឺថាគម្រោងកំពុងបង្កើតឡើងដោយគណៈកម្មការដោះស្រាយវិវាទថ្នាក់ស្រុក-ឃុំ មណ្ឌលសេវាយុត្តិធម៌ដែលមាន ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និង UNDP កំពុងធ្វើកិច្ចការនេះ ។ មកទល់នឹងឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាឃុំ ចំនួន ៨០កំពុងត្រូវបានទទួលការបណ្តុះបណ្តាល ។

លោក កាន់ វុទ្ធី អភិបាលរងខេត្តព្រះវិហារ បានលើកឡើងអំពីបញ្ហាឯករាជ្យភាពរបស់តុលាការ និងអំពីរដ្ឋបាលតុលាការទាក់ទងនឹងរបាយការណ៍ តើត្រូវផ្ញើជូន និងចតចម្លង ជូនថ្នាក់ខេត្តដែរឬទេ ? សំណួរ មួយទៀតទាក់ទងទៅនឹងកំហុសឆ្គងពាក់ព័ន្ធនឹងវិជ្ជាជីវៈតុលាការដែលកាត់ក្តីខុសនីតិវិធី តើយើងអាចប្តឹងទារ សងជម្ងឺចិត្តបានដែរឬទេ ?

ឯកឧត្តម ស៊ុយ ម៉ុងលាង បានឆ្លើយតបនឹងសំណួរខាងលើដូចតទៅ ៖

- ឯករាជ្យភាពរបស់តុលាការ គឺឯករាជ្យនៅលើការកាត់ក្តីដោយមិនមានអំណាចអ្វីមួយមកកៀបសង្កត់
- រដ្ឋបាលតុលាការឋិតនៅក្រោមការត្រួតត្រារបស់ក្រសួងយុត្តិធម៌ បើសិនជាមានរបាយការណ៍ គឺត្រូវផ្ញើទៅក្រសួងយុត្តិធម៌ ហើយក្នុងរបាយការណ៍នោះ មិននិយាយអំពីការកាត់ក្តីទេ គឺនិយាយ តែពីរបាយការណ៍រដ្ឋបាលតុលាការប៉ុណ្ណោះ
- ចំពោះកំហុសឆ្គងរបស់ចៅក្រមក្នុងការកាត់ក្តីខុស ឯកឧត្តមបានលើកឡើងថា តុលាការមានបីថ្នាក់គឺ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ហេតុដូច្នេះ ប្រសិនបើការកាត់ក្តី នៅសាលាដំបូងនោះ យើងមិនសុខចិត្ត យើងអាចមានសិទ្ធិតវ៉ាទៅសាលាឧទ្ធរណ៍ និងតុលាការកំពូលបាន ដូច្នេះយើងមិនអាចដាក់កំហុស ចៅក្រមនោះទេ ព្រោះយើងមានសិទ្ធិតវ៉ា ហើយបើសិនជាតុលាការធ្វើខុសនីតិវិធីនោះមែន យើងក៏មានច្បាប់សម្រាប់អ្នកធ្វើខុសនោះដែរ ។

លោក ប្រែង សារុធ ប្រធានមន្ទីរផែនការមានការចាប់អារម្មណ៍បីចំណុច ៖ ទី១ទាក់ទិនទៅនឹងលទ្ធភាពទទួលបានព័ត៌មាន លោកមានប្រសាសន៍ថា ការផ្សព្វផ្សាយផ្នែកច្បាប់ដល់ប្រជាពលរដ្ឋមិនទាន់ជាសុះសាយនោះទេ ហេតុនេះលោកសំណូមពរអោយបន្ថែមនូវការផ្សព្វផ្សាយបន្ថែមទៀត ដើម្បីអោយប្រជាពលរដ្ឋ មានការយល់ដឹងអំពីច្បាប់គ្រប់គ្នា ។ ចំណុចទី២ គឺទាក់ទងទៅនឹងការត្រួតពិនិត្យការតាមដានវាយតម្លៃ ក្នុងការអនុវត្តច្បាប់ ថាតើស្ថាប័នណាអង្គភាពណាជាអ្នកទទួលខុសត្រូវក្នុងការវាស់វែងក្នុងការអនុវត្តច្បាប់ ។ ចំណុចទី៣គឺពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទី៤ គឺធ្វើ អោយប្រសើរឡើងនូវគុណភាពនូវគុណភាពនៃដំណើររឿងក្តី និងសេវាពាក់ព័ន្ធ ដោយលោកលើកឡើងករណីមួយថាមានគ្រួសារក្រីក្រមួយមានដីជម្រៅ ៣០ x ៥០ ដោយសារតែភាពក្រីក្រគាត់មិនបានធ្វើប្លង់ដីទេ ប៉ុន្តែមានអ្នកផ្សេងលួចធ្វើប្លង់រឹងថាជាកម្មសិទ្ធិរបស់គេវិញ ។ តាមអង្គហេតុពេលប្តឹងផ្តល់តុលាការបានកាត់ក្តីទៅអោយអ្នកមានប្លង់រឹងមានសិទ្ធិកាន់កាប់ដីទៅវិញ ប៉ុន្តែ បើពិនិត្យមើលភាពជាក់ស្តែងដីនោះ ជារបស់គ្រួសារក្រីក្រ ដូច្នេះលោកសំណូមពរសុំអោយតុលាការ មេត្តាជួយពិចារណារកខុសត្រូវជូន គ្រួសារក្រីក្រនេះផង ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានឆ្លើយតបនឹងចំណុចទី១ថា ចំណុចនេះពាក់ព័ន្ធនឹងទិសដៅជាយុទ្ធសាស្ត្រទី៣ ដែលបានជម្រាបជូនច្បាស់លាស់នៅខាងលើរួចមកហើយ ។ ត្រង់ចំណុចទី២ ឯកឧត្តម

បានឯកភាពទាក់ទងទៅនឹងការត្រួតពិនិត្យការតាមដានវាយតម្លៃក្នុងការអនុវត្តច្បាប់នោះផងដែរ ហើយចំពោះចំណុចទី៣ ឯកឧត្តមបានមានប្រសាសន៍ថា ជាសំណួរបច្ចេកទេសសុទ្ធសាធ ដូនេះពុំអាចឆ្លើយនឹងសំណួរ នេះបានទេ ។

នៅទីបញ្ចប់ឯកឧត្តម ស៊ុយ ម៉ុងលាង បានធ្វើការសរុបលទ្ធផលនៃអង្គសិក្ខាសាលា និងធ្វើការវាយតម្លៃខ្ពស់ចំពោះការចូលរួមមតិដ៏ផុសផុលរបស់អង្គប្រជុំ ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៨*

បានឃើញ និងឯកភាព
ជ.គណៈធិបតីនៃអង្គសិក្ខាសាលា

**អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងលាង**

**សេង វ៉ាន់ដា**

**ស៊ុន សិរីវុធ**